ក្រសួងមហាផ្ទៃ

ក្រសួងសង្គមកិច្ច អតីតយុទ្ធជន
និងយុវនីតិសម្បទា

# សៀវភៅណែនាំស្តីពី ការធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារនៅតាមគ្រួសារ និងការធ្វើសមាហរណកម្មកុមារ

## ចំនួន៣០% ពីមណ្ឌលថែទាំកុមារ ទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាពសម្រាប់គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (គ.ក.ន.ក)



**ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា**
អគារលេខ ៧៨៨ មហាវិថី ព្រះមុនីវង្ស
សង្កាត់បឹងត្របែក ខណ្ឌចំការមន រាជធានីភ្នំពេញ
ទូរស័ព្ទលេខ +៨៥៥ ២៣ ២១៤ ០៣៩
Email: phino.cwd@gmail.com
http://www.mosvy.gov.kh

# ហេតុផលដែលនាំឱ្យមានកូនសៀវភៅនេះ

ក្នុងនាមជាអង្គភាពផ្លូវការតែមួយគត់នៅកម្រិតថ្នាក់ឃុំ/សង្កាត់ ដែលទទួលខុសត្រូវលើកិច្ចការនារី និងកុមារ គណៈកម្មាធិការទទួលបន្ទុកកិច្ចការនារី និងកុមារឃុំ/សង្កាត់ (គ.ក.ន.ក) ដើរតួនាទីមួយដ៏សំខាន់ក្នុងការការពារកុមារនៅក្នុងសហគមន៍ សៀវភៅណែនាំនេះ គូសបញ្ជាក់អំពីតួនាទីរបស់ គ.ក.ន.ក ក្នុងការអនុវត្តផែនការសកម្មភាពដើម្បីធ្វើឱ្យប្រសើរឡើងនូវការថែទាំកុមារ ដែលកំពុងត្រូវបានអនុវត្តក្នុងរាជធានី ខេត្តអាទិភាពចំនួន៥ ក្នុងនោះរួមមាន រាជធានីភ្នំពេញ ខេត្តបាត់ដំបង ខេត្តសៀមរាប ខេត្តកណ្តាល និង ខេត្តព្រះសីហនុ។ ផែនការសកម្មភាពនេះ មានបំណងធ្វើការសមាហរណកម្មកុមារចំនួន៣០%ពីមណ្ឌលថែទាំកុមារ ទៅកាន់គ្រួសាររបស់ពួកគេវិញដោយសុវត្ថិភាពត្រឹមដំណាច់ឆ្នាំ ២០១៨ ព្រមទាំងបង្កើតឱ្យមានយន្តការបង្ការ និង ត្រួតពិនិត្យប្រកបដោយប្រសិទ្ធភាពដើម្បីទប់ស្កាត់ការបំបែកកុមារចេញពីគ្រួសារដែលមិនចាំបាច់។

ផែនការសកម្មភាពនេះត្រូវបានប្រកាសផ្សព្វផ្សាយក្នុងខែមេសា ឆ្នាំ២០១៧ ដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា( ស.អ.យ ) និង អង្គការយូនីសេហ្វ។ ការអនុវត្តផែនការសកម្មភាពនេះ កំពុងស្ថិតក្រោមការដឹកនាំរបស់ក្រសួង ស.អ.យ និងស្ថាប័នរដ្ឋាភិបាលនានា ដោយមានការគាំទ្រផ្នែកបច្ចេកទេស និងហិរញ្ញវត្ថុពីទីភ្នាក់ងារអភិវឌ្ឍន៍អន្តរជាតិរបស់សហរដ្ឋអាមេរិក អង្គការយូនីសេហ្វ និង កម្មវិធី ភាពជាដៃគូដើម្បីការពារកុមារ 3PC មានជាបណ្តាញអង្គការមិនមែនរដ្ឋាភិបាល ចំនួន១០ ដោយមានអង្គការ Friends-International ជាអ្នកសម្របសម្រួល។ ផែនការសកម្មភាពនេះមានលក្ខណៈស្របគ្នា ទៅនឹងគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារឆ្នាំ២០០៦ ប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ ឆ្នាំ២០១១ អនុក្រឹត្យលេខ១១៩ អនក្រ.បក ស្តីការការគ្រប់គ្រងមណ្ឌលថែទាំកុមារ ឆ្នាំ២០១៥ ក្របខ័ណ្ឌគតិយុត្តនានាពាក់ព័ន្ធនឹងការថែទាំជំនួស។ ដូច្នេះតួនាទីរបស់ គ.ក.ន.ក ដែលមាននៅក្នុងសៀវភៅនេះ គឺជាប្រមូលផ្តុំចេញមកពីគោលនយោបាយ ផែនការសកម្មភាព និងក្របខ័ណ្ឌច្បាប់ពាក់ព័ន្ធដែលមានស្រាប់ ។

សៀវភៅណែនាំនេះ មានសារៈប្រយោជន៍ក្នុងការពង្រឹងតួនាទីរបស់ គ.ក.ន.ក ក្នុងការលើកកម្ពស់ចំណេះដឹង និង សមត្ថភាព ដើម្បីការពារកុមារនៅក្នុងឃុំ/សង្កាត់។

## ហេតុអ្វីបានជាផែនការសកម្មភាពស្ដីពីការធ្វើសមាហរណកម្មកុមារ មានសារៈសំខាន់?

- មានកុមារច្រើនហួសប្រមាណកំពុងរស់នៅក្នុងមណ្ឌលថែទាំកុមារ៖ មានកុមារចំនួន ១៦.៥៧៩នាក់ កំពុងរស់នៅក្នុងមណ្ឌលចំនួន ៤០៦កន្លែង ( *"មណ្ឌលកុមារកំព្រា"*) ទូទាំងប្រទេស។ ៧៧%នៃកុមារទាំងនេះ យ៉ាងហោចណាស់មានឪពុក ឬ ម្ដាយម្នាក់ដែលនៅរស់ ដែលមានន័យថាពួកគេមិនគួរយកទៅដាក់ឱ្យរស់នៅក្នុងមណ្ឌលថែទាំនោះទេ ប៉ុន្តែគ្រួសាររបស់ពួកគាត់គប្បីទទួលបានការគាំទ្រដើម្បីថែទាំកូនរបស់ពួកគាត់នៅក្នុងគ្រួសារនិងសហគមន៍។
- ការស្រាវជ្រាវកម្រិតសកលជាច្រើនទស្សវត្សរ៍បានបង្ហាញឱ្យដឹងថា គ្រួសារ និងការថែទាំតាមគ្រួសារ គឺប្រសើរបំផុតសម្រាប់ការអភិវឌ្ឍន៍រាងកាយ អារម្មណ៍ ស្មារតីរបស់កុមារ ក្នុងការសំរេចនូវសក្ដានុពលពេញលេញរបស់ពួកគេ។ *"មណ្ឌលកុមារកំព្រា"* គួរតែជាជម្រើសចុងក្រោយ និង ជាដំណោះស្រាយបណ្ដោះអាសន្នប៉ុណ្ណោះ។ រាជរដ្ឋាភិបាលកម្ពុជាទទួលស្គាល់លទ្ធផលនៃការស្រាវជ្រាវនេះ និង ជឿថាតួនាទីបឋមក្នុងការការពារ និងថែទាំកុមារ គឺជាតួនាទីរបស់គ្រួសារ និងសហគមន៍។

| កុមារនៅក្នុងមណ្ឌលថែទាំកុមារកំព្រា អាចប្រឈមនឹងបញ្ហានឹងរងបទពិសោធន៍ដូចខាងក្រោម៖ | កុមារដែលទទួលបានការចិញ្ចឹមបីបាច់ថែរក្សានៅក្នុងបរិយាកាសគ្រួសារ ទទួលបាននឹងជួបប្រទះបទពិសោធន៍ដូចខាងក្រោម៖ |
|---|---|
| ការរំលោភបំពានផ្លូវភេទ និង ផ្លូវកាយ | បរិយាកាសដែលមានសុវត្ថិភាពជាង |
| មិនសូវទទួលបានការយកចិត្តទុកដាក់ពីអ្នកថែទាំ អាស្រ័យដោយកុមារមានចំនួនច្រើនពេក និង បុគ្គលិកមានចំនួនតិច ព្រមទាំងមានការផ្លាស់ប្ដូរបុគ្គលិកញឹកញាប់គួរឱ្យកត់សម្គាល់។សូមពិចារណា ឪពុកម្ដាយបង្កើតអាចថែទាំកូន១នាក់ទៅ៤នាក់ ប៉ុន្តែអ្នកថែទាំកុមារ១នាក់នៅក្នុងមណ្ឌលត្រូវបានឱ្យទទួលខុសត្រូវកុមារជាង៣០នាក់ ដែលមិនស្របទៅនឹងបទដ្ឋានអប្បបរមាស្ដីពីការថែទាំជំនួសចំពោះកុមារ២០០៨។ មានន័យថាកុមារមិនអាចទទួលបានសេចក្ដីស្រឡាញ់ ការយកចិត្តទុកដាក់ និងការគាំទ្រដែលពួកគេត្រូវការបានឡើយ។ | ទទួលបានការយកចិត្តទុកដាក់ ការស្រឡាញ់ និងការថែទាំច្រើនពីឪពុកម្ដាយបង្កើត។ |

<table>
<tr><td>ត្រូវបែកពីគ្រួសារ និង ដាច់ចេញពីសហគមន៍របស់ពួកគេ ម៉្យាងវិញទៀត កុមារដែលរស់នៅក្នុង “មណ្ឌលថែទាំកុមារ” យូរពេក មានការពិបាកក្នុងការវិលត្រឡប់ទៅរស់នៅជាមួយមិត្តភក្តិ និង គ្រួសាររបស់ពួកគេវិញ។</td><td>ជាចំណែកមួយនៃសហគមន៍ មានអារម្មណ៍ថាជាចំណែកមួយនៃគ្រួសារ មានទំនាក់ទំនងកាន់តែល្អជាមួយគ្រួសារ និង មិត្តភក្តិ នៅពេលដែលកុមារចម្រើនវ័យឡើង។</td></tr>
<tr><td colspan="2">មណ្ឌលថែទាំកុមារមួយចំនួនអាចមានកន្លែងស្នាក់នៅនិងសម្ភារល្អដែលអាចមានការទាក់ទាញចំពោះគ្រួសារក្រីក្រ។ ប៉ុន្តែ កុមារ ត្រូវការលើសពីការថែទាំផ្លូវកាយ គឺ ពួកគេត្រូវការក្តីស្រឡាញ់ ការយកចិត្តទុកដាក់ និង ការផ្សាភ្ជាប់ ទំនាក់ទំនងយូរអង្វែងជាមួយអ្នកថែទាំកុមារ ដែលអ្វីទាំងអស់នេះ ពួកគេមិនអាចទទួលបានពីអ្នកដែលពួកគេមិនធ្លាប់ស្គាល់នៅក្នុងមណ្ឌលថែទាំកុមារឡើយ។</td></tr>
<tr><td colspan="2">ការថែទាំតាមមណ្ឌលបង្កឱ្យមាននូវការខូចខាត ជាពិសេសចំពោះកុមារអាយុក្រោម៣ឆ្នាំ ដោយសារតែរយៈពេលប៉ុន្មានឆ្នាំដំបូង គឺជាដំណាក់កាលអភិវឌ្ឍន៍សំខាន់បំផុតនៅក្នុងជីវិតរបស់កុមារ។ ការយកកុមារទៅដាក់ក្នុងមណ្ឌល បង្កឱ្យរាំងស្ទះដល់ការអភិវឌ្ឍន៍ផ្លូវកាយ និង សតិបញ្ញា។ ការស្រាវជ្រាវបង្ហាញឱ្យដឹងថា រៀងរាល់រយៈពេល៣ខែ ដែលកុមារតូចម្នាក់រស់នៅក្នុងមណ្ឌល នាំឱ្យពួកគេបាត់បង់ការអភិវឌ្ឍន៍រយៈពេល១ខែ។ កុមារតូចដែលបានប្តូរពីមណ្ឌល ទៅរស់នៅជាមួយឪពុកម្តាយធម៌ក្រោមជំនួយឧបត្ថម្ភនានា មុនអាយុ២ឆ្នាំ មានការវិវឌ្ឍន៍យ៉ាងខ្លាំងគួរឱ្យកត់សម្គាល់ បើធៀបទៅនឹងកុមារដែលស្នាក់នៅក្នុងមណ្ឌល។</td></tr>
</table>





## តើ គ.ក.ន.ក មានតួនាទីអ្វីខ្លះ ក្នុងការអនុវត្តន៍ ផែនការសកម្មភាពនេះ ?

គ.ក.ន.ក គប្បីត្រួតពិនិត្យទៅលើស្ថានភាពជារួមរបស់កុមារ ដែលកំពុងត្រូវបានសមាហរណកម្មពីមណ្ឌលថែទាំកុមារ គ.ក.ន.ក ត្រូវជួយកៀរគរធនធាននានាដើម្បីជួយគាំទ្រដល់កុមារនិងគ្រួសារ រាយការណ៍ពីស្ថានភាព និង បញ្ហាប្រឈមនានា នៅក្នុងកិច្ចប្រជុំក្រុមប្រឹក្សាឃុំសង្កាត់ដែលធ្វើឡើងជារៀងរាល់ខែ។ គ.ក.ន.ក ពន្យល់ ដល់ក្រុមប្រឹក្សាឃុំ/សង្កាត់ អំពីផែនការសកម្មភាពនូវតួនាទីសំខាន់ ៣។

| ១. ការបង្ការ | ២. ការទប់ស្កាត់ | ៣. ការធ្វើសមាហរណកម្ម/ការបង្រួបបង្រួមគ្រួសារ |
|---|---|---|

### ១. ការបង្ការ

#### សារៈសំខាន់នៃការបង្ការ

ការបង្ការ និងការថែរក្សាគ្រួសារ មានន័យថាជាការរក្សាកុមារឱ្យនៅ ជួបជុំគ្នាជាមួយគ្រួសាររបស់គាត់។ កុមារគ្រប់រូបមានសិទ្ធិដែលមិនអាចកាត់ផ្តាច់បាន ក្នុងការបន្តរស់នៅប្រកបដោយសុវត្ថិភាពជាមួយម្តាយ និង/ឬ ឪពុកបង្កើត ក្នុងករណីដែលអាចធ្វើទៅបាន។ ទំនាក់ទំនង រវាងឪពុកម្តាយ និងកូន គឺជាទំនាក់ទំនងមួយដ៏វិសេសវិសាល ដែលមិនគប្បីកាត់ផ្តាច់ឡើយ លុះត្រាណាតែមានការគំរាមកំហែងចំពោះសុវត្ថិភាពរបស់កុមារ។ ការបំបែកកុមារចេញពីគ្រួសារបង្កើតរបស់គេ គួរត្រូវបានពិចារណា លុះត្រាណាតែគ្រប់មធ្យោបាយទាំងអស់ ត្រូវបានប្រឹងប្រែងអស់លទ្ធភាព។ ក្នុងន័យនេះ តើ គ.ក.ន.ក អាចធ្វើអ្វីបានខ្លះ ?

ឧទាហរណ៍ ៖ ការគាំទ្រកុមារងាយរងគ្រោះ ដើម្បីបង្ការការបំបែកកុមារពីគ្រួសារ



សមាជិក គ.ក.ន.ក កំណត់រកកុមារ និងគ្រួសារ ដែលប្រឈមទៅនឹងការ បំបែកកុមារពីគ្រួសារ (សូមមើលបញ្ជីផ្ទៀងផ្ទាត់)។ កត់ត្រាអំពីទិន្នន័យនេះ។

ប៉ាន់ប្រមាណស្ថានភាពគ្រួសារ ៖ ឧ. តើគ្រួសារមានអាហារទទួលទានគ្រប់គ្រាន់ដែរឬទេ? តើកុមារបានទៅសាលារៀនដែរឬទេ? តើមានអំពើហិង្សាក្នុងគ្រួសារដែរឬទេ?តើកុមារទទួលបានការថែទាំសុខភាពពេលដែលគេឈឺដែរឬទេ?

ផ្តល់កិច្ចគាំទ្រដោយផ្ទាល់ (សូមមើលបញ្ជីផ្ទៀងផ្ទាត់) ប្រសិនបើគ្រួសារមិនអាចដោះស្រាយស្ថានភាពរបស់ពួកគេបាន។ សម្របសម្រួលជាមួយអាជ្ញាធរមូលដ្ឋាន និងអ្នកផ្តល់សេវាដទៃទៀតដែលអាចជួយដល់គ្រួសារនេះបាន។ ចុះសួរសុខទុក្ខដើម្បីតាមដានគ្រួសារទាំងនេះ។




**បញ្ជីផ្ទៀងផ្ទាត់ ៖ តើនរណាខ្លះដែលប្រឈមនឹងការបំបែកកុមារពីគ្រួសារ ?**

- កុមារនៃគ្រួសារក្រីក្រ
- កុមារដែលមានតែឪពុក ឬ ម្តាយ ឬ កុមារដែលពុំមានឪពុកម្តាយរស់នៅជាមួយ ឬកុមារកំពុងរស់នៅជាមួយអ្នកថែទាំជាចាស់ជរា (ដូចជា ជីដូនជីតា) ដែលមានការលំបាកក្នុងការថែទាំកុមារ
- កុមាររស់នៅក្នុងគ្រួសារដែលមានអំពើហិង្សា ធ្ងន់ធ្ងរ
- កុមាររស់នៅក្នុងគ្រួសារដែលកំពុងជួបប្រទះបញ្ហា ប្រើប្រាស់ គ្រឿងស្រវឹង លេងល្បែងស៊ីសង និង ការប្រើប្រាស់ គ្រឿងញៀន
- កុមាររស់នៅក្នុងគ្រួសារដែលកំពុងមានជំងឺរ៉ាំរ៉ៃ ឬមានពិការភាព
- កុមារនៃគ្រួសារដែលមានកូន កំពុងរស់នៅក្នុង "មណ្ឌលថែទាំកុមារ"
- កុមារកំពុងប្រឈម ឬកំពុងមានទំនាស់នឹងច្បាប់

**បញ្ជីផ្ទៀងផ្ទាត់ ៖ តើ គ.ក.ន.ក អាចផ្តល់កិច្ចគាំទ្រដោយផ្ទាល់អ្វីខ្លះ ?**

- ផ្តល់ដំបូន្មាននៅនឹងកន្លែង ដូចជាសារៈសំខាន់នៃការជៀសវាងប្រព្រឹត្តអំពើហិង្សា និង ការបញ្ជូនកូនទៅ សាលារៀន និងផ្តល់ការគាំទ្រផ្នែកវេជ្ជសាស្ត្រ និង អាហារូបត្ថម្ភ នៅពេលចាំបាច់
- បញ្ជូនគ្រួសារឱ្យទៅជួបអ្នកផ្តល់សេវាក្នុងមូលដ្ឋាន ឬ បញ្ជូនអ្នកផ្តល់សេវាក្នុងមូលដ្ឋានឱ្យទៅជួបគ្រួសារវិញ ដើម្បីផ្តល់សេវាមួយចំនួន ដូចជា កិច្ចគាំទ្រការអប់រំ កិច្ចគាំទ្រជីវភាពរស់នៅ កិច្ចគាំទ្រផ្នែកវេជ្ជសាស្ត្រ និងការផ្តល់ប្រឹក្សា
- ចុះសួរសុខទុក្ខតាមផ្ទះ ដើម្បីកំណត់ស្វែងរកករណីដែលមានការប្រឈមខ្ពស់បំផុត
- បញ្ជូនកុមារដែលមិនអាចរស់នៅជាមួយគ្រួសាររបស់ពួកគេបាន ទៅអ្នកផ្តល់សេវាថែទាំជំនួសតាមគ្រួសារ និង/ឬ តាមសហគមន៍ ដូចជា ការថែទាំដោយសាច់ញាតិ (រស់នៅជាមួយនិងសមាជិកនានារបស់គ្រួសារ) និងការថែទាំដោយឪពុកម្តាយធម៌ ។ សូមចងចាំថា "មណ្ឌលថែទាំកុមារ" គប្បីជាជម្រើសចុងក្រោយ និង ចំពោះតែក្នុងករណីដែលមិនអាចជៀសវាងបាន ហើយគប្បីជាដំណោះស្រាយបណ្តោះអាសន្នប៉ុណ្ណោះ
- អប់រំគ្រួសារ និង សហគមន៍អំពីផលប៉ះពាល់អវិជ្ជមាននៃការបំបែកកុមារពីគ្រួសារ និង លើកកម្ពស់ឱ្យមានការចិញ្ចឹមកូនបែបវិជ្ជមាន ដើម្បីការពារ និង ផ្តល់ការថែទាំឱ្យបានគ្រប់គ្រាន់សម្រាប់កុមារ នៅក្នុងសហគមន៍របស់ពួកគាត់។

សូមកុំភ្លេចរក្សាទុកនូវបញ្ជីរាយនាមអ្នកផ្តល់សេវានៅក្នុងសហគមន៍របស់អ្នក និង ឪពុកម្តាយធម៌។

## ២. ការទប់ស្កាត់

ការទប់ស្កាត់គឺជាដំណើរការបញ្ជូនកុមារ និង គ្រួសារទៅកាន់សេវា ឬ ការថែទាំសមស្របនានា ក្នុងគោលបំណង កម្រិត ចំនួននៃការទុកដាក់កុមារដែលមិនសមស្រប និង ចំនួនកុមារដែលចូលទៅរស់នៅក្នុង "មណ្ឌលថែទាំកុមារ"។ ដូចដែលមានចែងក្នុងប្រកាសស្តីពីនីតិវិធីអនុវត្តគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ និងផែនការពង្រឹងការថែទាំកុមាររបស់ក្រសួង ស.អ.យ. ក្នុងការកែលម្អការថែទាំកុមារ គឺតម្រូវឱ្យមាន

ហត្ថលេខាពី គ.ក.ន.ក មុនពេលដែលកុមារត្រូវបានទុកដាក់ឱ្យស្នាក់នៅក្នុងមណ្ឌល ដូច្នេះ គ.ក.ន.ក ត្រូវពិនិត្យឡើងវិញដោយប្រុងប្រយ័ត្នទៅលើករណីនីមួយៗដែលគេបានស្នើឡើង ដើម្បីធានាថារាល់ជម្រើសនៃការថែទាំជំនួសដទៃទៀតក្រៅពីមណ្ឌលថែទាំកុមារ ត្រូវបានពិនិត្យអស់លទ្ធភាព។ តើគ្រួសារបានទទួលកិច្ចគាំទ្រសមស្រប ដែរឬទេ? ប្រសិនបើការផ្តល់កិច្ចគាំទ្រសមស្របជូនគ្រួសារបង្កើត មិនអាចប្រព្រឹត្តទៅបាន តើគេបានស្វែងរកការថែទាំជំនួសជាលក្ខណៈគ្រួសារធម៌ គ្រួសារសាច់ញាតិ និងជម្រើសដទៃទៀតនៅសហគមន៍ ដែរឬទេ?

**ជម្រើសនៃការទុកដាក់កុមារ**

**ជម្រើសទី១** ៖ ការធំដឹងក្តីជាមួយឪពុកម្តាយបង្កើត

**ជម្រើសទី២** ៖ ជម្រើសថែទាំតាមគ្រួសារ ដូចជាការថែទាំដោយញាតិ សុំកូន ឬ ឪពុកម្តាយធម៌ (គ្រួសារដែលមិនមែនជាឪពុកម្តាយបង្កើតរបស់កុមារ)

**ជម្រើសទី៣** ៖ ជម្រើសថែទាំតាមសហគមន៍ ដូចជាផ្ទះស្នាក់នៅជាក្រុម (ផ្ទះតូចៗ ដែលរស់នៅក្នុងលក្ខណៈជាគ្រួសារ)

**ជម្រើសចុងក្រោយ** ៖ មណ្ឌលថែទាំកុមារ (*"មណ្ឌលកុមារកំព្រា"*) ដែលមានលក្ខខណ្ឌ ស្របទៅនឹងបទដ្ឋាន អប្បបរមារបស់រាជរដ្ឋាភិបាល

ការថែទាំជំនួសតាមគ្រួសារ ឬ សហគមន៍ មានលក្ខណៈប្រសើរជាងការថែទាំជំនួសតាមមណ្ឌល ប៉ុន្តែរាល់ការរៀបចំផ្តល់ការថែទាំកុមារទាំងអស់ ទាមទារឱ្យមានការត្រួតពិនិត្យតាមដាន ដើម្បីធានាសុវត្ថិភាព និងការថែទាំឱ្យបានសមស្របតាមគោលនយោបាយស្តីពីការថែទាំជំនួសដោយមានជំនួយបច្ចេកទេសពីក្រសួង/មន្ទីរ/ការិយាល័យ ស.អ.យ.។



**ជម្រើសទី១**



**ជម្រើសទី២**



ជម្រើសទី៣




ជម្រើសចុងក្រោយ

## ឧទាហរណ៍ ៖ ការត្រួតពិនិត្យដ៏ល្អ

នៅគ្រប់ដំណាក់កាលទាំងអស់ត្រូវធានាចំពោះឧត្តមប្រយោជន៍របស់កុមារ និង *“ការមិនបង្កការឈឺចាប់”* ការបំបែកកុមារពីគ្រួសារត្រូវតែជាជម្រើសចុងក្រោយបង្អស់ មានន័យថា មិនត្រូវបញ្ជូនកុមារទៅមណ្ឌល ជាជម្រើសទី១ឡើយ។

គ.ក.ន.ក ទទួលបានសំណើសុំទុកដាក់កុមារនៅកន្លែងថែទាំជំនួស ចំពោះកុមារ។

១). គ.ក.ន.ក ធ្វើការប៉ាន់ប្រមាណស្ថានភាពគ្រួសារ។ តើបានធ្វើអ្វីៗគ្រប់យ៉ាងដើម្បីជួយរក្សាគ្រួសារឱ្យនៅជួបជុំគ្នាហើយឬនៅ?

២). តើមានជម្រើសអ្វីខ្លះ ដែលត្រូវបានពិចារណាសម្រាប់ការថែទាំជំនួសតាមគ្រួសារ (ការថែទាំដោយឪពុកម្តាយធម៌ សាច់ញាតិ) និងសហគមន៍។ ចំណុចនេះគប្បីប្រើប្រាស់នៅក្នុងស្ថានភាពដែលគ្រួសារមិនអាចរស់នៅជាមួយគ្នាបាន ឬរកមិនឃើញសមាជិកគ្រួសារណាម្នាក់។

ចំពោះជម្រើសចុងក្រោយ និង បណ្តោះអាសន្ន គប្បីបញ្ជូនកុមារទៅមន្ទីរ ស.អ.យ ដើម្បីទុកដាក់កុមារនៅក្នុងមណ្ឌល (ដើម្បីផ្តល់ការអនុញ្ញាតជាផ្លូវការ)
សូមចងចាំ ៖ កុមារអាយុក្រោម៣ឆ្នាំ មិនគួរទុកដាក់នៅក្នុងមណ្ឌលថែទាំកុមារឡើយ។ ផ្តល់អាទិភាពចំពោះជម្រើសថែទាំតាមគ្រួសារ ដូចជាការថែទាំដោយ គ្រួសារធម៌ និង ការថែទាំដោយញាតិ។

## ៣. ការធ្វើសមាហរណកម្ម

គឺជាដំណើរការនៃការបង្រួមបង្រួមកុមារដែលកំពុងរស់នៅក្នុងមណ្ឌលថែទាំត្រឡប់ទៅកាន់គ្រួសារ និងសហគមន៍ដែលជាផ្នែកមួយនៃប្រកាសស្តីពីនិតិវិធីអនុគោលនយោបាយស្តីពីការថែទាំជំនួសចំពោះកុមារ និង ផែនការពង្រឹងការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន៣០ភាគរយពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាពពីឆ្នាំ២០១៦-ឆ្នាំ២០១៨ របស់ក្រសួង ស.អ.យ នេះគឺជាដំណើរការមួយដ៏វែងឆ្ងាយ និង ស្មុគស្មាញ។ គ.ក.ន.ក អាចជួយដល់មន្ទីរ/ការិយាល័យ ស.អ.យ និង អង្គការមិនមែនរដ្ឋាភិបាល ក្នុងការស្វែងរកគ្រួសារបង្កើត និងសាច់ញាតិរបស់កុមារ ដែលនឹងត្រូវធ្វើសមាហរណកម្ម និង ធ្វើការប៉ាន់ប្រមាណទៅលើគ្រួសារទាំងនោះ មុនពេលនាំកុមារត្រឡប់ទៅផ្ទះរបស់ពួកគេវិញ។ គ.ក.ន.ក ត្រូវចុះហត្ថលេខាលើទម្រង់ពាក់ព័ន្ធនានានៃដំណើរការបង្រួបបង្រួមកុមារជាមួយគ្រួសារបង្កើត ឬគ្រួសារសាច់ញាតិរបស់ពួកគេ ឬទុកដាក់ពួកគេនៅក្នុងទម្រង់ណាមួយនៃការថែទាំជំនួសក្នុងសហគមន៍ ។

គ.ក.ន.ក គប្បីធ្វើការត្រួតពិនិត្យឱ្យបានដិតដល់ចំពោះកុមារគ្រប់រូប ដែលបានធ្វើសមាហរណកម្មពីមណ្ឌលវិញ ប្រមូលធនធាននានា និង តាមដាន ទៅលើសេចក្តីត្រូវការរបស់ពួកគេ។ គ.ក.ន.ក គួរចុះមើលកុមារទាំងនេះ និង រាយការណ៍ទៅការិយាល័យ ស.អ.យ ឬ មន្ទីរ ស.អ.យ អំពីស្ថានភាពរបស់កុមារ ដោយផ្តល់មតិយោបល់អំពីចំណាត់ការជាបន្ទាន់ ដើម្បីគាំទ្រកុមារដែលប្រឈម ក្រោយពេលធ្វើការបង្រួបបង្រួមជាមួយគ្រួសាររបស់ពួកគេ។ កុមារត្រូវការឱ្យមានកិច្ចគាំទ្រជាសម្ភារៈ និង កិច្ចគាំទ្រក្នុងទម្រង់ជាការផ្តល់មតិយោបល់ដទៃទៀត នៅក្នុងដំណើរការសមារហរណកម្មនេះ។ ប្រសិនបើចាំបាច់ សូមភ្ជាប់ទំនាក់ទំនងពួកគេជាមួយអ្នកផ្តល់សេវាពាក់ព័ន្ធ។ គ.ក.ន.ក គួរចែករំលែកពត៌មានអំពីកុមារដែលបានធ្វើសមាហរណកម្មរួច ជាមួយ គ.ក.ស.ក ស្រុក ដើម្បីអាចចែករំលែកព៌មានទាំងនេះក្នុងកិច្ចប្រជុំប្រចាំត្រីមាសជាមួយនិងក្រុមសមាហរណកម្មនៅថ្នាក់ខេត្តក្នុងខេត្តនិមួយៗ និងតាមដានលើចំណុចសកម្មភាពដែលគេបានពិភាក្សា និងអនុវត្ត ។

ឧទាហរណ៍ ៖ ការបញ្ជូនកុមារពីមណ្ឌលថែទាំកុមារ

ជួយដល់មន្ទីរ ស.អ.យ. និង អង្គការមិនមែនរដ្ឋាភិបាល ក្នុងការស្វែងរកគ្រួសារ ប៉ាន់ប្រមាណគ្រួសារ និង រៀបចំផែនការករណីរបស់កុមារ ដើម្បីឱ្យពួកគេអាចត្រូវបានសមាហរណកម្មពីមណ្ឌលថែទាំកត្រឡប់ទៅគ្រួសារក្នុងឃុំ/សង្កាត់របស់លោក លោកស្រី។

គាំទ្រដល់ការងារបង្រួបបង្រួមគ្រួសារជាក់ស្តែង ៖ ចុះហត្ថលេខាលើទម្រង់ពាក់ព័ន្ធនានានៃដំណើរការបង្រួបបង្រួមគ្រួសារ ឬ ទម្រង់ទុកដាក់កុមារឱ្យស្ថិតក្រោមការថែទាំជំនួសក្នុងសហគមន៍

ចុះធ្វើការតាមដានកុមារគ្រប់រូបដែលត្រូវបានបង្រួបបង្រួម ឬ ទុកដាក់នៅក្នុងទម្រង់នៃការថែទាំដទៃទៀត។ ប៉ាន់ប្រមាណអំពីស្ថានភាពរបស់ពួកគេ ដោយផ្អែកលើ *"បញ្ជីផ្ទៀងផ្ទាត់ការងារសមាហរណកម្ម"* (សូមមើលចំណុចខាងក្រោម)។

ផ្តល់កិច្ចគាំទ្រដែលចាំបាច់ និង ធ្វើការបញ្ជូនទៅអ្នកផ្តល់សេវាពាក់ព័ន្ធ (ដោយពិគ្រោះយោបល់ជាមួយមន្ទីរ ស.អ.យ.) ទៅតាមភាពចាំបាច់។ ពិភាក្សាអំពីករណីនានានៅក្នុងកិច្ចប្រជុំប្រចាំខែ។

**បញ្ជីផ្ទៀងផ្ទាត់ ៖ អ្វីដែលត្រូវស្វែងរកនៅពេលប៉ាន់ប្រមាណអំពីស្ថានភាពនៃការធ្វើសមាហរណកម្ម (បញ្ជីផ្ទៀងផ្ទាត់ អំពីការងារសមាហរណកម្ម)**

- កុមារបានទៅរៀន
- កុមារទទួលបានអាហារមូលដ្ឋាន និង ជម្រក
- កុមារទទួលបានការថែទាំសុខភាពនៅពេលដែលពួកគេឈឺ
- កុមារមិនបង្ហាញឱ្យឃើញអំពីសញ្ញានៃវិបត្តិផ្នែកចិត្តសង្គម និង ភាពមិនរីករាយ
- ពុំមានហានិភ័យទាក់ទងនឹងកិច្ចការពារកុមារ (ឧ. គ្រួសារដែលកុមារត្រូវបានទុកដាក់ឱ្យរស់នៅជាមួយ/បង្រួបបង្រួម មិនប្រើអំពើហិង្សា ឬ រំលោភបំពាន គ្មានការកេងប្រវ័ញ្ចពលកម្មកុមារ)
- កុមារ និង គ្រួសារ ពេញចិត្តទៅនឹងការរៀបចំនាពេលបច្ចុប្បន្នរបស់ពួកគេ
- កុមារចូលរួមនៅក្នុងព្រឹត្តិការណ៍សហគមន៍
- គ្រួសារមានស្ថេរភាពផ្នែកហិរញ្ញវត្ថុ ដើម្បីមើលថែទាំកុមារ។


សាលារៀន





## តើ គ.ក.ន.ក អាចសម្របសម្រួលរកសេវាសំខាន់អ្វីខ្លះដើម្បីផ្តល់កិច្ចគាំទ្រ ការបង្ការ ការទប់ស្កាត់ និងការធ្វើសមាហរណកម្មកុមារដែលងាយរងគ្រោះ ?

គ.ក.ន.ក គប្បីរក្សាកំណត់ហេតុផ្ទាល់ខ្លួនអំពីភ្នាក់ងារផ្តល់សេវាដែលមាន នៅក្នុងសហគមន៍មូលដ្ឋានរបស់ខ្លួន

បណ្តាញទូរស័ព្ទទាន់ហេតុការណ៍អំពីសុវត្ថិភាពកុមារ (ដំណើរការដោយសមាជិកនៃកម្មវិធី 3PC)៖

**០១២ ៣១១ ១១២ (ភ្នំពេញ)**

**០១៧ ៣៥៨ ៧៥៨ (សៀមរាប)**

**០១២ ៤៧៨ ១០០ (ព្រះសីហនុ)**

បណ្តាញទូរស័ព្ទទាន់ហេតុការណ៍របស់នគរបាលជាតិ៖

**១២៨៨ ឬ**

**០២៣ ៩៩៧ ៩១៩**

បណ្តាញទូរស័ព្ទជំនួយកុមារកម្ពុជា ៖

ទូរស័ព្ទទៅលេខ **១២៨០ ឬ**

ផ្ញើសារទៅលេខ **០១៧ ៩៨៥ ៨១០**

## តើ គ.ក.ន.ក គប្បីអនុវត្តតាមគោលការណ៍អ្វីខ្លះ នៅពេលធ្វើការងារទាក់ទងនឹងសមាហរណកម្ម?

**ឧត្តមប្រយោជន៍របស់កុមារ ៖** ចំណុចនេះត្រូវតែជាការពិចារណាបឋមក្នុងការធ្វើសេចក្តីសម្រេចចិត្តនានាដែលអាច បង្កឱ្យមានផលប៉ះពាល់ទៅលើកុមារ។ នីតិជនគ្រប់រូប គប្បីគិតថា តើការសម្រេចចិត្តរបស់ពួកគេនឹងបង្កឱ្យមានផលប៉ះពាល់ដូចម្តេចខ្លះចំពោះកុមារ ព្រមទាំងគោរពទៅលើសុចរិតភាពផ្លូវកាយ ផ្លូវចិត្ត សីលធម៌ និង ស្មារតី របស់កុមារផងដែរ។ សេចក្តីថ្លៃថ្នូររបស់កុមារ គប្បីត្រូវបានលើកកម្ពស់។ សូមចងចាំថា កុមារគ្រប់រូបមានស្ថានភាពជាក់លាក់ មានដំណើររឿង និង សេចក្តីត្រូវការផ្ទាល់ខ្លួន។

**ចំណុចគន្លឹះ ៖** ការបំបែកកុមារពីគ្រួសារគប្បីជាជម្រើសចុងក្រោយ ដូចជាក្នុងករណីដែលកុមារអាចប្រឈមទៅនឹង គ្រោះថ្នាក់ដែលបម្រុងនឹងកើតឡើងក្នុងពេលឆាប់ៗខាងមុខ។ រាល់សេចក្តីសម្រេចចិត្តពាក់ព័ន្ធនឹងការថែទាំជំនួស គប្បីខិតខំរក្សាកុមារឱ្យស្ថិតនៅក្បែរលំនៅដ្ឋានរបស់កុមារបំផុតទៅតាមដែលអាចធ្វើបាន ដើម្បីសម្របសម្រួលឱ្យកុមារអាចប្រាស្រ័យទាក់ទង និង ធ្វើសមាហរណកម្មជាមួយគ្រួសារបាន ព្រមទាំងកាត់បន្ថយការកាត់សង្វាក់ចំពោះការអប់រំ វប្បធម៌ និង ជីវិតសង្គមរបស់កុមារ។

**ការមិនបង្កគ្រោះថ្នាក់ ៖** *"ការមិនបង្កគ្រោះថ្នាក់"* មានន័យថា សុខុមាលភាពរបស់កុមារមិនត្រូវធ្លាក់ចុះ ឬ កាត់បន្ថយឡើយ ទោះក្រោមស្ថានភាពណាក៏ដោយ។ រាល់ដំណើរការធ្វើសមាហរណកម្មទាំងអស់ គប្បីមានគោលដៅផ្តល់ប្រយោជន៍ចំពោះកុមារ និង មិនត្រូវបង្កគ្រោះថ្នាក់ដល់សុវត្ថិភាពផ្លូវកាយ និង ផ្លូវចិត្តរបស់ពួកគេឡើយ។

**សមធម៌ ៖** សិទ្ធិមូលដ្ឋានរបស់កុមារគ្រប់រូប ដោយមិនប្រកាន់ភេទ ជាតិសាសន៍ សាសនា ប្រាក់ចំណូល ប្រភេទពិការភាព ទីតាំងភូមិសាស្ត្រ ឬ ស្ថានភាពដទៃទៀត គប្បីទទួលបានកិច្ចការពារ។ ការយកចិត្តទុកដាក់ជាក់លាក់ គប្បីផ្តល់ជូនកុមារដែលមានសេចក្តីត្រូវការពិសេស ដើម្បីធានាថាពួកគេមិនត្រូវបានមើលរំលង និងមិនមានការរើសអើង។

**បញ្ជីផ្ទៀងផ្ទាត់ ៖ តើ គ.ក.ន.ក គួររក្សាទិន្នន័យអ្វីខ្លះ ?**

- ចំនួនកុមារងាយរងគ្រោះ ដែលប្រឈមនឹងការបំបែកពីគ្រួសារ
- ចំនួនកុមារដែលបានធ្វើសមាហរណកម្មពី *"មណ្ឌលថែទាំកុមារទៅកាន់គ្រួសារបង្កើត គ្រួសារសាច់ញាតិ ឬ ទម្រង់នៃការថែទាំដទៃទៀតក្នុងសហគមន៍ និងស្ថានភាពរបស់ពួកគេ"*
- ចំនួនកុមារដែលបានទទួលការគាំទ្រពី គ.ក.ន.ក (សម្រាប់ការបង្ការ ទប់ស្កាត់ និង សមាហរណកម្ម ដូចជា ការស្វែងរកគ្រួសារ ការបង្រួបបង្រួមគ្រួសារ ការពិនិត្យតាមដាន ការបញ្ជូន)
- ចំនួនអ្នកផ្តល់សេវាថែទាំជំនួសនៅក្នុងឃុំ/សង្កាត់របស់អ្នក និង កុមារដែលរស់នៅកន្លែងទាំងនោះ
- ចំនួនកុមារដែលបានចូលស្នាក់នៅក្នុងមណ្ឌលថែទាំកុមារ (នៅក្នុងខេត្តរបស់អ្នក)
- ចំនួនកុមារដែល គ.ក.ន.ក បានបញ្ជូន ដើម្បីទៅស្នាក់នៅក្នុងមណ្ឌល និងប្រភេទការថែទាំជំនួសដទៃទៀត។



# សទ្ទានុក្រម

| | |
|---|---|
| **CCWC** | Commune Committee for Women and Children |
| **DoSVY** | Department of Social Affairs, Veterans and Youth Rehabilitation |
| **NGO** | Non-Governmental Organization |
| **OSVY** | Office of Social Affairs, Veterans and Youth Rehabilitation |
| **RCI** | Residential Care Institution |
| **WCCC** | Women and Children Consultative Committee |
| **3PC** | Partnership Programme for the Protection of Children |

# ករណីសិក្សា

## ១.អំពីកិច្ចគាំទ្រដើម្បីបង្ការ

ក្នុងខេត្តសៀមរាប មានជីដូនម្នាក់បានមកជួបជនបង្គោល គ.ក.ន.ក ដើម្បីធ្វើការទុកដាក់ចៅស្រីម្នាក់របស់គាត់ឱ្យស្នាក់នៅក្នុង *"មណ្ឌលថែទាំកុមារ"*។ ថ្មីៗនេះ ឪពុកម្ដាយរបស់កុមារបានធ្វើចំណាកស្រុកទៅប្រទេសថៃ ហើយជីដូនម្នាក់នេះ ពុំមានលទ្ធភាពអាចមើលថែចៅៗរបស់គាត់បាន។ ជនបង្គោល គ.ក.ន.ក បានប្រាប់គាត់អំពីគុណសម្បត្តិនៃការរស់នៅជាមួយគ្រួសារ និង គុណវិបត្តិរបស់ *"មណ្ឌលថែទាំកុមារ"*។ ក្រោយពេលពិគ្រោះយោបល់ជាមួយសមាជិកដទៃទៀតរបស់ គ.ក.ន.ក រួចមក ជនបង្គោលបានភ្ជាប់ទំនាក់ទំនងគ្រួសារនេះជាមួយ អង្គការមិនមែនរដ្ឋាភិបាលមួយក្នុងមូលដ្ឋាន។ អង្គការមិនមែនរដ្ឋាភិបាល នៃកម្មវិធី 3PC បានធ្វើការងារជាមួយ គ្រួសារនេះ ដើម្បីរក្សាពួកគេឱ្យរស់នៅជួបជុំគ្នា ដោយផ្ដល់កិច្ចគាំទ្រលើការអប់រំ និងការបង្កើតប្រាក់ចំណូល។ បើទោះបីជាគ្រួសារនេះនៅតែបន្តជួបប្រទះការលំបាកយ៉ាងណាក្ដី ប៉ុន្តែពួកគេកំពុងខិតខំប្រឹងប្រែងដើម្បីធ្វើឱ្យស្ថានភាពរបស់ពួកគេមានភាពប្រសើរឡើង ហើយពួកគេមានភាពសប្បាយរីករាយដែលបានរស់នៅជួបជុំគ្នា។




សៀវភៅ

## ២. កិច្ចគាំទ្របង្ការ/ថែរក្សាគ្រួសារ

សុវណ្ណ* ដែលមានភាពវៃឆ្លាត និង ឧស្សាហ៍ព្យាយាមក្នុងការរៀនសូត្រ គឺជាសិស្សឆ្នើមម្នាក់នៅថ្នាក់ទី៧។ ប៉ុន្តែ នាពេលថ្មីៗនេះ នៅក្នុងឆ្នាំសិក្សាចុងក្រោយ លទ្ធផលសិក្សារបស់នាងមិនសូវល្អទៀយ។ បញ្ហាលំបាកផ្នែកហិរញ្ញវត្ថុធ្ងន់ធ្ងរលើគ្រួសាររបស់សុវណ្ណ បានធ្វើឱ្យនាងមិនអាចសម្រេចបាននូវសក្តានុពលរបស់នាង។

ឪពុករបស់សុវណ្ណ ឈ្មោះផាន់* គឺជាអ្នករត់រឺម៉កម៉ូតូកង់បី ហើយគាត់បានធ្លាក់ខ្លួនឈឺកាលពីឆ្នាំមុន។ ក្រោយមក រឺម៉កម៉ូតូរបស់គាត់បានខូច។ ដោយមានមនុស្សចំនួន ៧នាក់ រស់នៅក្រោមដំបូលផ្ទះតែមួយ វាកាន់តែមានការលំបាកក្នុងការរស់នៅ។ ធី* ដែលជាភរិយា និង ជាម្តាយ ក៏ចាប់ផ្តើមដើររើសអេតចាយ។ ដោយសារតែម្តាយចាប់ផ្តើមចេញធ្វើការងារ ដូច្នេះ សុវណ្ណក៏ចូលទៅជួយការងារក្នុងផ្ទះ និង ជួយមើលប្អូនៗរបស់នាង។ នាងតែង ខកខានទៅសាលារៀនជាញឹកញាប់។ បើទោះបីជាគ្រួសារនេះបានខឹតខំប្រឹងប្រែងយ៉ាងណាក៏ដោយ ប៉ុន្តែ ស្ថានភាពមិនបានប្រសើរឡើងឡើយ។ ពួកគេអស់សង្ឃឹមយ៉ាងខ្លាំង។

ពួកគេត្រូវបានអង្គការមិនមែនរដ្ឋាភិបាល នៃកម្មវិធី 3PC កំណត់ថាជាគ្រួសារប្រឈម ដោយអង្គការនេះបានជួយ សុវណ្ណឱ្យវិលត្រឡប់ទៅសាលារៀនវិញ ព្រមទាំងត្រួតពិនិត្យលើការរៀនសូត្ររបស់នាងនៅឯសាលាផងដែរ។ អង្គការនេះក៏បានជួយជួសជុលរឺម៉កម៉ូតូកង់បីឱ្យគ្រួសារនេះថែមទៀតផង។ ផាន់ បានមានភាពធូរស្រាលពីជំងឺ ហើយឥឡូវនេះគាត់អាចរកប្រាក់ចំណូលជាថ្មីម្តងទៀត។

ឥឡូវនេះ សុវណ្ណ បានវិលត្រឡប់មកជីវិតជាក្មេងស្រីជំទង់របស់នាងវិញ ហើយនាងស្រម៉ៃថាចង់ក្លាយជាវេជ្ជបណ្ឌិតមួយរូប ដើម្បីជួយដល់ប្រជាជនកម្ពុជា។




សាលារៀន

## ៣. សមាហរណកម្ម

បន្ទាប់ពីបានរស់នៅដោយមិនសប្បាយចិត្ត ក្នុង *"មណ្ឌលថែទាំកុមារ"* អស់រយៈពេល៣ឆ្នាំក្នុងខេត្តបាត់ដំបងមក ឥឡូវនេះ ដារា* ដែលមានអាយុ ១១ឆ្នាំ និង វណ្ណា ដែលមានអាយុ៨ឆ្នាំ កំពុងវិលត្រឡប់ទៅទទួលការថែទាំពី គ្រួសាររបស់ពួកគេវិញ ក្រោយពេលដែលមានកម្មវិធីអន្តរាគមន៍មួយដឹកនាំដោយរដ្ឋាភិបាល បានបង្រួបបង្រួមគ្រួសាររបស់ពួកគេ។

ឪពុកម្តាយរបស់ក្មេងប្រុសទាំងពីរនេះ បានទុកដាក់ពួកគេឱ្យរស់នៅក្នុង *"មណ្ឌលថែទាំកុមារកំព្រា"* មុនពេលដែលពួកគេធ្វើចំណាកស្រុកទៅប្រទេសថៃ ដើម្បីធ្វើការងារជាកម្មករសំណង់។

ដើម្បីសម្រេចផែនការពង្រឹងការថែទាំកុមារ និងសមាហរណកម្មកុមារចំនួន៣០ភាគរយពីមណ្ឌលថែទាំកុមារទៅកាន់គ្រួសារប្រកបដោយសុវត្ថិភាព បុគ្គលិកសង្គមរបស់មន្ទីរ ស.អ.យ បានធ្វើការគ្រប់គ្រងករណីកុមារដែលកំពុងស្នាក់នៅក្នុងមណ្ឌលថែទាំកុមារដែលដារា និង វណ្ណា បានរស់នៅហើយកុមារភាគច្រើនមានឪពុក ឬ ម្តាយ ម្នាក់នៅរស់ ហើយមណ្ឌលថែទាំកុមារ មិនបានបំពេញតាមតម្រូវការដែលកុមារគ្រប់រូបចង់បាន។

បុគ្គលិកសង្គមកិច្ច សហការជាមួយគ.ក.ន.ក និងអ្នកពាក់ព័ន្ធ ធ្វើការ ស្វែងរកនិងការប៉ាន់ប្រមាណគ្រួសារ ឪពុកម្តាយរបស់កុមារ ឬ សមាជិកគ្រួសារដទៃទៀត។



ដារា និង វណ្ណា ត្រូវបានបង្រួបបង្រួមជាមួយឪពុកម្ដាយរបស់ពួកគេ ក្នុងខែមករា ឆ្នាំ២០១៦។ បុគ្គលិក សង្គមកិច្ច បានធ្វើការងារយ៉ាងជិតស្និទ្ធជាមួយ គ.ក.ន.ក និងអ្នកពាក់ព័ន្ធ ក្នុងមូលដ្ឋាន ដើម្បីសម្របសម្រួលដំណើរការនេះ។ ពួកគេបានចុះសួរសុខទុក្ខដើម្បីធ្វើការតាមដាន ផ្ដល់ប្រឹក្សាយោបល់ និង រៀបចំឱ្យកុមារទាំងពីរនាក់នេះចុះឈ្មោះចូលរៀនឡើងវិញនៅឯសាលាបឋមសិក្សា។

វណ្ណា បានប្រាប់បុគ្គលិកសង្គមកិច្ចថា *"ខ្ញុំមានអារម្មណ៍ថាមានសុវត្ថិភាព និង មានសន្តិសុខល្អខ្លាំងណាស់នៅពេលដែលខ្ញុំបានត្រឡប់មកដល់ផ្ទះវិញ។" "ម្ដាយរបស់ខ្ញុំបានឱបខ្ញុំ។ ខ្ញុំសប្បាយចិត្តខ្លាំងណាស់ដែលបានលេងជាមួយមិត្តភក្តិជិតខាង និង មិត្តភក្តិនៅឯសាលារៀន។"*

ដារា ក៏មានអារម្មណ៍ដូចគ្នាផងដែរ។ គាត់បាននិយាយថា *"គ្រួសាររបស់ខ្ញុំមើលថែទាំខ្ញុំបានល្អ"*។ *"ខ្ញុំចូលចិត្តគ្រូបង្រៀនរបស់ខ្ញុំ និង មិត្តភក្តិនៅឯសាលារៀន។"*

បុគ្គលិកសង្គមកិច្ចរបស់មន្ទីរ ស.អ.យ បានសហការណ៍ជាមួយបុគ្គលិកសង្គមកិច្ចរបស់អង្គការមិនមែនរដ្ឋាភិបាល ក្នុងមូលដ្ឋាន នៃកម្មវិធី 3PC ដើម្បីផ្ដល់កិច្ចគាំទ្របន្ថែមសម្រាប់គ្រួសារ ដោយផ្ដោតលើការអប់រំ និង ជីវភាពរស់នៅ។ ម្ដាយរបស់កុមារាបានប្រាប់ឱ្យដឹងថា គាត់នឹងមិនបញ្ជូនកូនរបស់គាត់ទៅមណ្ឌលកុមារកំព្រាទៀតឡើយ។ *"ខ្ញុំឯកោខ្លាំងណាស់នៅពេលដែលគ្មានពួកគេ។ ខ្ញុំសប្បាយចិត្តណាស់ដែលពួកគេត្រឡប់មកផ្ទះវិញ។"*



## ៤. សមាហរណកម្ម

រ៉ាវី* អាយុ១២ឆ្នាំ ដែលមានបញ្ហាពិការសតិបញ្ញាបន្តិចបន្តួច រស់នៅជាមួយម្តាយរបស់នាង និង បងបង្កើតរបស់នាងចំនួន២នាក់ទៀត នៅភ្នំពេញ។ នៅពេលដែលនាងឈ្លោះប្រកែកគ្នាជាមួយម្តាយរបស់នាង ក្មេងស្រីម្នាក់នេះ បានរត់ចេញពីផ្ទះ ជិះរថយន្តក្រុងទៅខេត្តព្រះសីហនុ។ មន្ត្រីនគរបាលម្នាក់ដែលធ្វើការងារនៅក្នុងតំបន់នោះបានឃើញ រ៉ាវី ចុះពីលើរថយន្តក្រុង និង បានកត់សម្គាល់អំពីភាពមិនប្រក្រតីដែលក្មេងស្រីតូចដ៏ស្មៀមស្ងាត់ម្នាក់ធ្វើដំណើរតែម្នាក់ឯង។ បន្ទាប់ពីបានទៅជួបនិយាយជាមួយកុមារីម្នាក់នេះបន្តិចមក មន្ត្រីនគរបាលរូបនេះក៏បានទូរស័ព្ទហៅអ្នករត់ម៉ូតូឌុបបណ្តាញសុវត្ថិភាពកុមារ ដែលប្រចាំការនៅក្បែរនោះ។ ភ្នាក់ងារបណ្តាញសុវត្ថិភាពកុមារ បានទូរស័ព្ទទៅបណ្តាញទូរស័ព្ទទាន់ហេតុការណ៍របស់បណ្តាញសុវត្ថិភាពកុមារដែលប្រចាំការ២៤ម៉ោង និងរក្សាការសម្ងាត់ របស់អង្គការមិនមែនរដ្ឋាភិបាល នៃកម្មវិធី 3PC។ បន្ទាប់មកក្រុមការងារការពារកុមាររបស់អង្គការមិនមែនរដ្ឋាភិបាល នៃកម្មវិធី 3PC ក៏ត្រូវបានបញ្ជូនដើម្បីឱ្យមកជួបក្មេងស្រីម្នាក់នោះ និង ក្រោយមកបានធ្វើការងារ ជាមួយអាជ្ញាធរមូលដ្ឋាន និង សមាជិក គ.ក.ន.ក ដើម្បីនាំ រ៉ាវី ត្រឡប់ទៅភ្នំពេញឱ្យរស់នៅរួបរួមគ្នាជាមួយគ្រួសាររបស់នាងវិញ។

* ឈ្មោះត្រូវបានប្តូរដើម្បីការពារអត្តសញ្ញាណរបស់គ្រួសារ។





unicef
ដើម្បីកុមារគ្រប់រូប

3PC
Together, building stronger child protection systems

USAID
FROM THE AMERICAN PEOPLE